# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

### Infographic
"How to Take Advantages of FTA?"

### Policy Brief
"How to Maximize the Utilization of Cambodia's Free Trade Agreements?"

*CHINKET Tola, HOR Iengchhay, and Prof. Dr. Shandre Mugan THANGAVELU*

វ៉ុល០២ | លេខ០៦ | ខែធ្នូ ឆ្នាំ២០២២
VOLUME 02 | ISSUE 06 | DECEMBER 2022

រៀបចំដោយ

សូមស្កេនដើម្បីទាញយក
iTrade Bulletin

# តើធ្វើដូចម្ដេចដើម្បីទាញយក អត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ?

## ៥ ជំហាន ដើម្បីពិចារណាសម្រាប់ការនាំចូល និងនាំចេញ

FTA
ចូលជាធរមាន

**កំណត់**
ចំណាត់ថ្នាក់ពន្ធ
និងការអនុគ្រោះពន្ធ

**សិក្សា**
លក្ខណៈវិនិច្ឆ័យនៃ
វិធានប្រភពដើម

**សិក្សា**
ការវិភាគផលចំណេញ - ថ្លៃចំណាយ
នៃប្រតិបត្តិការរបស់អ្នក

ការទទួលបាន
ចូលក្នុង
ប្រព័ន្ធអនុគ្រោះ

**សិក្សា**
ច្បាប់គយសម្រាប់
ការនាំចេញ-នាំចូល

## ក្របខ័ណ្ឌពហុភាគី

ការចូលជាសមាជិក
**អាស៊ាន**
១៩៩៩

ការចូលជាសមាជិក
**អង្គការពាណិជ្ជកម្មពិភពលោក**
២០០៤

## កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី

**កិច្ចព្រមព្រៀង
ពាណិជ្ជកម្មសេរីកម្ពុជា-ចិន
(CCFTA)**
ចុះហត្ថលេខាឆ្នាំ២០២០

**កិច្ចព្រមព្រៀង
ពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ
(CKFTA)**
ចុះហត្ថលេខាឆ្នាំ២០២១

## កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់

**កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងចិន**
*ចុះហត្ថលេខាឆ្នាំ២០០២*

**កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងឥណ្ឌា**
*ចុះហត្ថលេខាឆ្នាំ២០០៣*

**កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន**
*ចុះហត្ថលេខាឆ្នាំ២០០៣*

**កិច្ចព្រមព្រៀងក្របខ័ណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន និងកូរ៉េ**
*ចុះហត្ថលេខាឆ្នាំ២០០៥*

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង**
*ចុះហត្ថលេខាឆ្នាំ២០១៨*

**កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់**
*ចុះហត្ថលេខាឆ្នាំ២០០៩*

**កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់**
*ចុះហត្ថលេខាឆ្នាំ២០២០*

## ការប្រៀបធៀបកម្រិតសេរីភាវូបនីយកម្មច្រកចូលទីផ្សារ ដែលកម្ពុជាទទួលបាន

| កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ | កិច្ចព្រមព្រៀងអាសិប | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន | កិច្ចព្រមព្រៀងអាសិប | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន |
| --- | --- | --- | --- | --- | --- |
| (HSK 2017) | (HSK 2012) | (HSK 2019) | (HS Code 2012) | (HS Code 2012) | (HS Code 2017) |
| ៨៩,៩៨% | ៩០,៦៣% | ៩៥,០៣% | ៩៤,៧៨% | ៩៥,៨៩% | ៩៧,៥៣% |
| (១១២៩៤ បន្ទាត់ពន្ធ) | (១១០៩៦ បន្ទាត់ពន្ធ) | (១១៦២៦ បន្ទាត់ពន្ធ) | (៧៨៤៩ បន្ទាត់ពន្ធ) | (៧៩៣៧ បន្ទាត់ពន្ធ) | (៨,៣៣៦ បន្ទាត់ពន្ធ) |

Organized by

Please scan to download iTrade Bulletin

# HOW TO TAKE ADVANTAGE OF FTAs?

## 5 STEPS TO CONSIDER FOR IMPORT & EXPORT

FTA INTO EFFECT

**DETERMINE** tariff classification and tariff preference

**STUDY** Rule of Origin criterias

**STUDY** cost-benefit analysis of your operation

**CLAIM** preferential access

**STUDY** import-export customs rule

## MULTILATERAL FRAMEWORKS

Accession to **ASEAN** *1999*

Accession to **World Trade Organization** *2004*

## BILATERAL FTAs

**Cambodia-China Free Trade Agreement** (CCFTA) *signed in 2020*

**Cambodia-Korea Free Trade Agreement** (CKFTA) *signed in 2021*

## REGIONAL FTAs

**Framework Agreement on Comprehensive Economic Co-operation between ASEAN and China** *signed in 2002*

**Framework Agreement on Comprehensive Economic Cooperation between ASEAN and India** *signed in 2003*

**ASEAN-Japan Comprehensive Economic Partnership Agreement** *signed in 2003*

**Framework Agreement on Comprehensive Economic Cooperation between ASEAN and Korea** *signed in 2005*

**ASEAN-Hong Kong, China Free Trade Agreement** *signed in 2018*

**ASEAN-Australia-New Zealand Free Trade Agreement (AANZFTA)** *signed in 2009*

**Regional Comprehensive Economic Partnership (RCEP)** *signed in 2020*

## MARKET ACCESS LIBERALIZATION FOR CAMBODIA COMPARISONS

| ASEAN-Korea FTA | RCEP | CKFTA | ASEAN-China FTA | RCEP | CCFTA |
|---|---|---|---|---|---|
| (HSK 2017) | (HSK 2012) | (HSK 2019) | (HS Code 2012) | (HS Code 2012) | (HS Code 2017) |
| 89.98% | 90.63% | 95.03% | 94.78% | 95.89% | 97.53% |
| (11,294 Tariff Lines) | (11,096 Tariff Lines) | (11,626 Tariff Lines) | (7,845 Tariff Lines) | (7,937 Tariff Lines) | (8,336 Tariff Lines) |

## សម្តេចនាយករដ្ឋមន្ត្រី គូសបញ្ជាក់ពីវិស័យដែលមានសក្តានុពលសម្រាប់កិច្ចសហប្រតិបត្តិការរវាង អាស៊ាន និងសហភាពអឺរ៉ុប នាពេលអនាគត

ប្រភព៖ Khmer Times

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានអាស៊ានឆ្នាំ២០២២ បានគូសបញ្ជាក់ពីវិស័យចម្បងៗ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងសហភាពអឺរ៉ុប នាពេលអនាគត។ កិច្ចសហប្រតិបត្តិការនឹងផ្តោតលើវិស័យជាអាទិភាពជាច្រើន រួមមាន៖ ការដឹកជញ្ជូន ការតភ្ជាប់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមានគុណភាព ពាណិជ្ជកម្មនិងវិនិយោគ ការពង្រឹងមីក្រូសហគ្រាសនិងសហគ្រាសធុនតូចនិងមធ្យម ការបំប្លែងថាមពល បច្ចេកវិទ្យានិងសេដ្ឋកិច្ចឌីជីថល ចំណីអាហារនិងកសិកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ ការផ្លាស់ប្តូរធនធានមនុស្ស និងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពត្រឹមឆ្នាំ២០៣០។ សម្តេច ហ៊ុន សែន បានលើកឡើងបែបនេះក្នុងកិច្ចសម្ភាសន៍ជាលាយលក្ខណ៍អក្សរជាមួយសារព័ត៌មាន EURACTIV មុនកិច្ចប្រជុំកំពូលអាស៊ាន-សហភាពអឺរ៉ុប ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ឆ្នាំនៃការបង្កើតទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុប។ ចុចទីនេះដើម្បីអានបន្ថែម

## ការនាំចេញរបស់កម្ពុជាទៅអាម៉េរិកមានតម្លៃជាង ៨ ប៊ីលានដុល្លារក្នុងរយៈពេល ១១ខែ

ប្រភព៖ Khmer Times

កម្ពុជា បាននាំចេញទំនិញក្នុងទំហំទឹកប្រាក់ ៨,២១ ប៊ីលានដុល្លារទៅទីផ្សារអាម៉េរិកក្នុងរយៈពេល ១១ខែ នៃឆ្នាំ២០២២។ តួលេខនេះ តំណាងឱ្យកំណើនប្រមាណ ២៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយយោងតាមរបាយការណ៍ចុងក្រោយរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។ ទំនិញកម្ពុជាសរុបប្រមាណ ៤០% ត្រូវបាននាំចេញទៅអាម៉េរិកក្នុងអំឡុងខែមករាដល់ខែវិច្ឆិកា។ អាម៉េរិកនៅតែជាប្រទេស ដែលបានទិញផលិតផលពីកម្ពុជាច្រើនជាងគេ បន្ទាប់ពីប្រទេសវៀតណាម ចិន ជប៉ុន កាណាដា និងអាល្លឺម៉ង់។ ទន្ទឹមនឹងនេះ របាយការណ៍ដដែលបានគូសបញ្ជាក់ថា កម្ពុជាបាននាំចូលទំនិញ ២៩២,៧ លានដុល្លារ ពីអាម៉េរិក ធ្លាក់ចុះ ៤,៨% ធៀបនឹងឆ្នាំមុន។ ការនាំចេញសំខាន់ៗរបស់កម្ពុជាទៅកាន់អាម៉េរិកមានដូចជា វាយនភណ្ឌ ស្បែកជើង ផលិតផលធ្វើដំណើរ និងផលិតផលកសិកម្ម ខណៈដែលការនាំចូលសំខាន់មានដូចជា យានយន្ត ចំណីសត្វ និងគ្រឿងម៉ាស៊ីន។ ចុចទីនេះដើម្បីអានបន្ថែម

## ក្រសួងជំរុញកសិករទៅចុះបញ្ជីដើម្បីនាំចេញម្រេចទៅចិន

ប្រភព៖ Khmer Times

ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទបានអំពាវនាវដល់កសិករនិងម្ចាស់រោងចក្រកែច្នៃម្រេចទៅចុះបញ្ជីត្រួតពិនិត្យគុណភាពដើម្បីនាំចេញម្រេចទៅទីផ្សារចិន។ ការអំពាវនាវនេះ ធ្វើឡើងបន្ទាប់ពីកម្ពុជានិងចិនទើបតែចុះហត្ថលេខាលើពិធីសារស្តីពីលក្ខខណ្ឌតម្រូវអនាម័យនិងភូតគាមអនាម័យសម្រាប់ការនាំចេញម្រេច។ តាមសេចក្តីជូនដំណឹងក្រសួង បានអំពាវនាវដល់ម្ចាស់ចំការម្រេច សហករដាំម្រេច និងម្ចាស់រោងចក្រកែច្នៃនិងវេចខ្ចប់ម្រេច ដែលមានបំណងនាំចេញម្រេចទៅទីផ្សារចិន មកដាក់ពាក្យស្នើសុំចុះបញ្ជីនៅអគ្គនាយកដ្ឋានកសិកម្ម។ ពិធីសារនេះ ក៏នឹងផ្តល់លទ្ធភាពដល់ក្រសួងស្ថាប័នជំនាញនៃប្រទេសទាំងពីរបន្តការចរចាលើលក្ខខណ្ឌតម្រូវ ដើម្បីអនុញ្ញាតឱ្យកម្ពុជាអាចនាំចេញម្រេចដោយផ្ទាល់ទៅទីផ្សារចិន។ បច្ចុប្បន្ននេះ កម្ពុជាមានផ្ទៃដីដាំម្រេចជាង ៦.៧០០ ហិកតា ដែលទទួលបានផលជាមធ្យមប្រមាណ ៣០.០០០ តោន។ ចុចទីនេះដើម្បីអានបន្ថែម

## ក្រុមហ៊ុនជាង ២០.០០០ បានចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

ប្រភព៖ Khmer Times

របាយការណ៍របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឱ្យដឹងថា គិតត្រឹមខែធ្នូ ឆ្នាំ២០២២ ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានបានអនុម័តយល់ព្រមចុះបញ្ជីក្រុមហ៊ុនចំនួន ២០.១៨៩ ស្មើនឹងទុនវិនិយោគសរុប ៥,៧០ ប៊ីលានដុល្លារអាម៉េរិក ។ ក្រៅពីនេះ ពាណិជ្ជនាមចំនួន ១២.៧៤២ កំពុងស្ថិតក្នុងដំណាក់កាលត្រួតពិនិត្យ ដើម្បីទទួលបានការអនុម័តយល់ព្រម ខណៈពាណិជ្ជនាមចំនួន២ ត្រូវបានបដិសេធ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មានកាលពីខែមិថុនា ឆ្នាំ២០២២។ អាជីវកម្មថ្មីៗអាចចុះបញ្ជីតាមរយៈប្រព័ន្ធនេះ ដោយអាចផ្តល់និងទទួលឯកសារជាកញ្ចប់ក្នុងទម្រង់ឌីជីថល។ ការប្រើប្រាស់ប្រព័ន្ធនេះនឹងជួយកាត់បន្ថយរាល់នីតិវិធីស្មុគស្មាញ តម្រូវការព័ត៌មានដដែលៗ ពេលវេលា និងថ្លៃចំណាយដែលធ្លាប់មានកន្លងមក។ ក្រសួង និងស្ថាប័នចំណុះរាជរដ្ឋាភិបាលជាច្រើនរួមមានក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានធ្វើសមាហរណកម្មរួមបញ្ចូលតែមួយក្នុងប្រព័ន្ធចុះបញ្ជីអាជីវកម្មនេះ។ ចុចទីនេះដើម្បីអានបន្ថែម

## Cambodian PM Highlights Potential Areas for Future ASEAN-EU Cooperation

Source: Khmer Times

Hun Sen, Prime Minister of the Kingdom of Cambodia and Chair of ASEAN 2022, has emphasized key areas for intensifying future cooperation between ASEAN and EU. Priority areas of cooperation will include, among others: transport, connectivity and quality infrastructure development; trade and investment; strengthening of MSMEs; energy transition; digital economy and technology; food and agriculture; science, technology, and innovation; people-to-people exchanges; and the attainment of Sustainable Development Goals (SDGs) by 2030, Hun Sen told EURACTIV Media in a written interview ahead of the ASEAN-EU Commemorative Summit to celebrate the 45th Anniversary of ASEAN-EU Dialogue Relations. Click here to read more

## Cambodia's Exports to U.S. Worth over $8 Billion in 11 Months

Source: Khmer Times

Cambodia exported $8,217 million worth of products to the U.S. market in the first eleven months of this year. The figure represents an increase of about 23 percent compared to the same period last year, according to the latest report from the General Department of Customs and Excise (GDCE) at the Ministry of Economy and Finance. About 40 percent of Cambodia's total exported goods went to the U.S. during the January-November period. The U.S. remained the largest buyer of Cambodia's products, followed by Vietnam, China, Japan, Canada, and Germany. Meanwhile, Cambodia imported $292.7 million worth of goods from the U.S., a year-on-year decrease of 4.8 percent, pointed out the same report. Cambodia's major exports to the U.S. include textiles, footwear, travel goods and agricultural products, while its main imports are vehicles, animal feed and machinery. Click here to read more

## Farmers Urged to Register for China Peppercorn Export

Source: Khmer Times

The Ministry of Agriculture, Forestry and Fisheries has called for farmers and processing plant owners to register for quality inspection related to the export of peppercorn to China. The call was made after Cambodia and China recently signed a protocol on phytosanitary requirements for the export of peppercorns. In a statement on Monday, the ministry said that pepper plantation owners, pepper agricultural cooperatives, and pepper processing and packaging factories that wish to produce and process pepper, and export peppercorn to the Chinese market, may apply for registration of pepper plantations and processing facilities for exporting pepper to China at the ministry's General Department of Agriculture (GDA). The newly-signed protocol paves the way for the two countries' specialised ministries and institutions to continue negotiations on phytosanitary requirements to allow Cambodian pepper to be directly exported to China. Currently, the area of pepper land is over 6,700 hectares, with an average yield of about 30,000 tons. Click here to read more

## Over 20,000 biz Registered with MEF Single Portal

Source: Khmer Times

As of December 12, 20,189 businesses had been approved with a total capital of $5.70 billion, according to a report from the Online Business Registration System under the Ministry of Economy and Finance. Some 12,742 business names of companies are in the stage of approval, the report said, adding that two business names have been rejected. The government launched the online business registration system, known as the Single Portal, in June 2022. New businesses can register on the packet information system, and all other documents can be provided and received in digital form. Through this platform, complex procedures, repetitive information, time and cost incurred under the old process will be minimized. Several ministries and state-run institutions – the Ministry of Commerce, General Department of Taxation, Ministry of Labor and Vocational Training, Ministry of Interior, and Council for the Development of Cambodia – have been integrated into a business registration system on the platform. Click here to read more

## សហភាពអឺរ៉ុបសម្រេចបាននូវកិច្ចព្រមព្រៀងសំខាន់មួយស្តីពីពន្ធលើការបំពុលបរិស្ថានសម្រាប់ទំនិញនាំចូល

ប្រភព៖ CNBC

ផែនការរបស់សហភាពអឺរ៉ុប លើយន្តការកែសម្រួលពន្ធលើឧស្ម័នកាបូនិកនៅព្រំដែន បានបោះជំហានទៅមុខគួរឱ្យកត់សម្គាល់ បន្ទាប់ពីកិច្ចព្រមព្រៀងបណ្តោះអាសន្នរវាងក្រុមប្រឹក្សាសហភាពអឺរ៉ុប និងសភាអឺរ៉ុបបានឈានដល់ការព្រមព្រៀងគ្នា។ ផែនការនេះ គឺយន្តការចាំបាច់ក្នុងគោលដៅដ៏ធំរបស់សហភាពអឺរ៉ុប ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់យ៉ាងហោចណាស់៥៥% ត្រឹមឆ្នាំ២០៣០។ ការយកពន្ធលើឧស្ម័នកាបូនិកនៅព្រំដែន នឹងមានវិសាលភាពលើទំនិញនាំចូលតាមវិស័យដូចជា អគ្គិសនី ជី អាលុយមីញ៉ូម ស៊ីម៉ងត៍ ដែកថែប និងដែក។ យន្តការកែសម្រួលពន្ធលើឧស្ម័នកាបូនិកនៅព្រំដែន ជាអ្វីដែលសហភាពអឺរ៉ុបគ្រោងនឹងបង្កើតដោយយកពន្ធឱ្យស្មើនឹងកាបូនដែលបានបញ្ចេញ។ មានតែទំនិញនាំចេញពីប្រទេស ដែលមានគោលបំណងគាំពារអាកាសធាតុដូចគ្នានឹងសហភាពអឺរ៉ុបប៉ុណ្ណោះ ទើបអាចនាំចូលអឺរ៉ុបបាន ដោយពុំចាំបាច់ទិញវិញ្ញាបនបត្រអនុញ្ញាតបញ្ចេញឧស្ម័នកាបូនិកនោះទេ ។ ចុចទីនេះដើម្បីអានបន្ថែម

## កាលានុវត្តភាពជាច្រើន ដែលអាជីវកម្មខ្នាតតូចមិនបានដឹង

ប្រភព៖ World Economic Forum

ក្នុងចំណោមក្រុមហ៊ុនទាំងអស់ ៩០% គឺជាក្រុមហ៊ុនខ្នាតតូច ដែលបានរួមចំណែកប្រមាណ ៧០% នៃការងារ និងផលិតផលក្នុងស្រុកសរុបនៅទូទាំងពិភពលោក។ ការស្រាវជ្រាវថ្មីៗ បានគូសបញ្ជាក់ថា៦៧% នៃសហគ្រាសធុនតូច និងមធ្យម បង្ហាញពីកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែលជាបញ្ហាប្រឈមដ៏សំខាន់។ របាយការណ៍ប្រចាំឆ្នាំ បានរកឃើញថា អាជីវកម្មកាន់តែតូច កាន់តែមានកាលានុវត្តភាពក្នុងការពង្រីកអាជីវកម្ម នវានុវត្តន៍ និងនិរន្តរភាពសេដ្ឋកិច្ចសកល តំបន់ និងក្នុងស្រុក។ យោងតាមរបាយការណ៍ បញ្ហាប្រឈមសំខាន់ៗប្រមាណ ៦៧% ដែលកំពុងកើតមាន នៃប្រតិបត្តិការរបស់សហគ្រាសធុនតូច និងមធ្យម គឺការបន្តនិរន្តរភាព និងពង្រីកអាជីវកម្ម ហើយស្ទើរតែពាក់កណ្តាលនៃសហគ្រាសទាំងនេះ បានបង្ហាញថា ទេពកោសល្យអាជីវកម្ម ក៏ជាបញ្ហាប្រឈមសំខាន់មួយដែរ។ ចុចទីនេះដើម្បីអានបន្ថែម

## ឌីជីថលូបនីយកម្មជួយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុក្នុងចំណោមយុវជនអាស៊ាន

ប្រភព៖ World Economic Forum

របាយការណ៍ថ្មីមួយ បានបង្ហាញថា ឌីជីថលូបនីយកម្មជួយលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុកាន់តែប្រសើរក្នុងចំណោមយុវជនឌីជីថលអាស៊ាន។ របាយការណ៍ស្តីពីជំនាន់ឌីជីថលអាស៊ានឆ្នាំ២០២២ របស់វេទិកាសេដ្ឋកិច្ចពិភពលោក បង្ហាញថា អាស៊ានមានកំណើនឌីជីថលូបនីយកម្ម ដែលមិនធ្លាប់មានពីមុន ហើយនិន្នាការនេះនឹងនៅតែបន្តទៅមុខទៀត។ ការទទួលបានសេវាហិរញ្ញវត្ថុឌីជីថលក៏កំពុងកើនឡើងនៅទូទាំងតំបន់ផងដែរ។ យ៉ាងណាក៏ដោយ របាយការណ៍នេះ បានរកឃើញថា ស្ត្រី ម្ចាស់មីក្រូអាជីវកម្ម សហគមន៍ជនបទ និងក្រុមងាយរងគ្រោះផ្សេងទៀត មានគម្លាតក្នុងការទទួលបានសេវាហិរញ្ញវត្ថុនៅក្នុងតំបន់។ ចុចទីនេះដើម្បីអានបន្ថែម

## សហភាពអឺរ៉ុបស្នើឱ្យក្រុមប្រឹក្សានៃអង្គការពាណិជ្ជកម្មពិភពលោក ដោះស្រាយវិវាទពាណិជ្ជកម្មជាមួយចិន

ប្រភព៖ ALJAZEERA

វិវាទពាក់ព័ន្ធនឹងការចោទប្រកាន់លើការរឹតត្បិតរបស់ចិនលើសិទ្ធិរបស់ក្រុមហ៊ុនសហភាពអឺរ៉ុបក្នុងការប្រើតុលាការបរទេស ដើម្បីការពារប្រកាសនីយបត្រតក្កកម្ម បច្ចេកវិទ្យាជាន់ខ្ពស់របស់ខ្លួន និងការធ្វើពាណិជ្ជកម្មជាមួយលីទុយអានី ដែលជាសមាជិកសហភាពអឺរ៉ុប។ គណៈកម្មាធិការសហភាពអឺរ៉ុបបាននិយាយនៅក្នុងសេចក្តីថ្លែងការណ៍ថា "ក្នុងករណី

ទាំងពីរ វិធានការនេះធ្វើឱ្យខូចខាតយ៉ាងខ្លាំងដល់អាជីវកម្មអឺរ៉ុប" ហើយវិធានការប្រឆាំងនឹងលីទុយអានីបានរំខានដល់ពាណិជ្ជកម្មនិងខ្សែច្រវាក់ផ្គត់ផ្គង់ក្នុងសហភាពអឺរ៉ុប។ វិវាទនេះ ធ្វើឱ្យមានក្តីបារម្ភពីការទម្លាក់កម្រិតទំនាក់ទំនងការទូតរវាងចិននិងលីទុយអានីចាប់ពីខែធ្នូ ឆ្នាំ២០២១ និងការដាក់សម្ពាធលើប្រទេសនានាដើម្បីផ្តាច់ទំនាក់ទំនងជាមួយប្រជាជាតិបាល់ទិកដែលមានប្រជាជនចំនួន ២,៨ លាននាក់ បន្ទាប់ពីលីទុយអានី បានអនុញ្ញាតឱ្យបើកស្ថានទូតតៃវ៉ាន់នៅទីក្រុងវីលនីញូស។ ក្នុងករណីមួយទៀត គណៈកម្មាធិការបាននិយាយថា ចាប់តាំងពីខែសីហា ឆ្នាំ២០២០ តុលាការចិនបានចេញ "ដីកាប្រឆាំងបណ្តឹង" ដែលរារាំងក្រុមហ៊ុនអឺរ៉ុប ស្វែងរកសំណងលើប្រកាសនីយបត្រតក្កកម្មស្តង់ដារសំខាន់ៗនៅក្នុងតុលាការបរទេស ដូចជាតុលាការសហភាពអឺរ៉ុបជាដើម។ ចុចទីនេះដើម្បីអានបន្ថែម

## ចិនកំពុងត្រៀមកញ្ចប់ថវិកាចំនួន១៤៣ប៊ីលានដុល្លារសម្រាប់ជួយក្រុមហ៊ុនបន្ទះឈីបរបស់ខ្លួនក្នុងការប្រឈមមុខនឹងការរឹតត្បិតរបស់អាមេរិក

ប្រភព៖ The Economic Times

ចិនកំពុងរៀបចំកញ្ចប់ជំនួយជាង ១ ទ្រីលានយន់ (១៤៣ ប៊ីលានដុល្លារ) សម្រាប់ឧស្សាហកម្មឧបករណ៍អេឡិចត្រូនិកពាក់កណ្តាលចម្លង (semiconductor) របស់ខ្លួនក្នុងជំហានដ៏សំខាន់មួយឆ្ពោះទៅកេការគ្រប់គ្រងការផលិតបន្ទះឈីបដោយខ្លួនឯង និងទប់ទល់នឹងគោលនយោបាយអាមេរិក ដែលមានបំណងកាត់បន្ថយភាពជឿនលឿនផ្នែកបច្ចេកវិទ្យារបស់ខ្លួន។ ចិនគ្រោងនឹងដាក់ចេញកញ្ចប់លើកទឹកចិត្តសារពើពន្ធដ៏ធំបំផុតរបស់ខ្លួនក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ដែលភាគច្រើននៃឧបត្ថម្ភធន និងឥណទានពន្ធគឺដើម្បីជំរុញផលិតកម្ម និងសកម្មភាពស្រាវជ្រាវឧបករណ៍អេឡិចត្រូនិកពាក់កណ្តាលចម្លងរបស់ខ្លួន។ ជាមួយនឹងកញ្ចប់លើកទឹកចិត្តនេះផងដែរ ចិនក៏មានគោលបំណងបង្កើនការគាំទ្រដល់ក្រុមហ៊ុនបន្ទះឈីបរបស់ខ្លួន ក្នុងការសាងសង់ពង្រីក ឬធ្វើទំនើបកម្មគ្រឿងបរិក្ខារក្នុងស្រុកសម្រាប់ការផលិត ការផ្គុំ ការវេចខ្ចប់ និងការស្រាវជ្រាវនិងអភិវឌ្ឍន៍។ ចុចទីនេះដើម្បីអានបន្ថែម

## អង្គការរូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកបង្ហាញសញ្ញាអាសន្នចំពោះសេដ្ឋកិច្ចសកល

ប្រភព៖ Bloomberg

អង្គការរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងអង្គការអន្តរជាតិដទៃទៀត បានបង្ហាញក្តីបារម្ភលើបញ្ហាកំណើនសេដ្ឋកិច្ចសកលមិនល្អ ប៉ុន្តែសង្ឃឹមថាការបើកប្រទេសឡើងវិញរបស់ចិន នឹងអាចជួយស្រោចស្រង់កំណើនសេដ្ឋកិច្ចសកលបាន។ ថ្មីៗនេះ អង្គការរូបិយវត្ថុអន្តរជាតិ បានព្យាករណ៍ថាសេដ្ឋកិច្ចសកលឆ្នាំ២០២៣ នឹងមានកំណើនត្រឹមតែ២,៧% ដែលធ្លាក់ចុះពី ៣,២% ក្នុងឆ្នាំ២០២២។ លើសពីនេះ ប្រធានធនាគារពិភពលោក ដាវិដ ម៉ាល់ផាស់ បានបង្ហាញក្តីបារម្ភយ៉ាងខ្លាំងថា ពិភពលោកកំពុងឋិតនៅក្បែរមាត់ច្រកនៃវិបត្តិសេដ្ឋកិច្ចសកល ដែលប៉ះពាល់លើប្រទេសកំពុងអភិវឌ្ឍន៍រយៈពេលវែង។ ជាមួយគ្នានេះដែរ លោកស្រី ង៉ូហ្ស៊ី អូកុនចូ អ៊ីវ៉ាឡា អគ្គនាយិកាអង្គការពាណិជ្ជកម្មពិភពលោក បានវាយតម្លៃថា ពាណិជ្ជកម្មសកលនឹងមានកំណើនទាបប្រមាណ១% ប៉ុណ្ណោះនៅឆ្នាំ២០២៣ ដែលធ្លាក់ចុះពី៣,៥% ក្នុងឆ្នាំ២០២២នេះ។ ចិនគួរតែកាត់បន្ថយអធិរេកស្តុកស្បៀងអាហារនិងជីរបស់ខ្លួន ដើម្បីជួយដល់ប្រទេសដែលខ្វះខាត និងជួយពិភពលោកពីស្ថិតាផរណា។ ចុចទីនេះដើម្បីអានបន្ថែម

### European Union reaches landmark agreement on a pollution tax for imports

Source: CNBC

Plans for the European Union's Carbon Border Adjustment mechanism took a significant step forward after a provisional deal between the Council of the EU and members of the European Parliament was reached. The CBAM is a significant cog in the EU's broader goal to cut greenhouse gas emissions by at least 55% by the year 2030. It will cover a range of goods and sectors such as electricity, fertilizers, aluminium, cement, steel and iron. Carbon Border Adjustment Mechanism, the EU has a plan to create a levy to equalize the price of carbon. Only countries with the same climate ambition as the EU will be able to export to the EU without buying CBAM certificates. Click here to read more

### The big opportunity behind small businesses

Source: World Economic Forum

Smaller companies represent 90% of all companies and are responsible for nearly 70% of both jobs and gross domestic product (GDP) worldwide. Recent Forum research highlights that 67% of SMEs and mid-sized companies report fighting for survival as their top challenge. A Year On report finds that smaller businesses have what it takes to enable widespread growth, innovation and sustainability in our global, regional and local economies. According to the report, the top challenge currently preoccupying 67% of executives of SMEs is survival and expansion and almost half of them highlight talent as one of their main challenges. Click here to read more

### Digitalization helps promote financial inclusion among ASEAN youth

Source: World Economic Forum

Digitalization can unlock greater financial inclusion among the ASEAN digital generation, according to a new report. The ASEAN region has seen unprecedented growth in digitalization, and this trend looks set to continue, according to the World Economic Forum's ASEAN Digital Generation Report 2022. The uptake of digital financial services is also increasing across the region. However, the report found that women, micro-business owners, rural communities, and other underserved groups experience gaps in accessing financial services in the region. Click here to read more

### EU requests WTO panels over trade disputes with China

Source: ALJAZEERA

The disputes concern alleged Chinese restrictions on EU companies' rights to use a foreign court to protect their high-tech patents, and trade with EU member Lithuania. "In both cases, the measures are highly damaging to European businesses," the Commission said in a statement, adding that measures against Lithuania disrupted intra-EU trade and supply chains. One of the disputes concerns China's downgrading of diplomatic ties with Lithuania from December 2021 and pressure on multinationals to sever links with the Baltic nation of 2.8 million people after it allowed Taiwan to open a de facto embassy in Vilnius. In the other case, the Commission said Chinese courts had since August 2020 issued "anti-suit injunctions" that prevent European companies from seeking redress over standard-essential patents in non-Chinese courts, such as EU courts. Click here to read more

### China readying $143 billion package for its chip firms in face of US curbs

Source: The Economic Times

China is working on a more than 1 trillion yuan ($143 billion) support package for its semiconductor industry in a major step towards self sufficiency in chips and to counter U.S. moves aimed at slowing its technological advances. China plans to roll out what will be one of its biggest fiscal incentive packages over five years, mainly as subsidies and tax credits to bolster semiconductor production and research activities at home. With the incentive package, China aims to step up support for Chinese chip firms to build, expand or modernise domestic facilities for fabrication, assembly, packaging, and research and development. Click here to read more

## IMF, World Bank Sound Alarm about Global Economic Outlook

Source: Bloomberg

The International Monetary Fund, World Bank and others raised concerns about a worsening global outlook, while hopeful that China's reopening will help support world growth. The IMF currently forecasts global growth will be 2.7% in 2023, slowing from 3.2% in 2022. David Malpass, head of the World Bank, was deeply concerned that the world is at risk of a global recession, which is a true long-term crisis for people in developing countries. Ngozi Okonjo-Iweala, director general of the WTO, estimated global goods trade will only grow 1% next year, a sharp slowdown from the estimated 3.5% expansion this year. China will have to reduce its excess stocks of food and fertilizer to help with shortages elsewhere to lift the world out of stagflation. Click here to read more

## សង្ខេបគោលនយោបាយ

# តើធ្វើដូចម្តេចដើម្បីទាញយកប្រយោជន៍ជាអតិបរិមាពីការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានារបស់កម្ពុជា?

**ជិនកេត តុលា**
អនុប្រធានការិយាល័យនៃវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ
ក្រសួងពាណិជ្ជកម្ម ព្រះរាជាណាចក្រកម្ពុជា

**ហោ អៀងឆាយ**
ប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ
ក្រសួងពាណិជ្ជកម្ម ព្រះរាជាណាចក្រកម្ពុជា

**ថៃងការ៉ាលូ សនជ្រេ មុហ្គាន**
ទីប្រឹក្សាក្រសួងពាណិជ្ជកម្ម ព្រះរាជាណាចក្រកម្ពុជា
វិទ្យាស្ថាន Jeffrey Cheah សម្រាប់តំបន់អាស៊ីអាគ្នេយ៍ នៃសាកលវិទ្យាល័យសាន់វេយ៍
វិទ្យាស្ថានពាណិជ្ជកម្មអន្តរជាតិ សាកលវិទ្យាល័យអាដេឡែដ

## ១.សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ថ្មីៗនេះ យើងបានឃើញពីការកើនឡើងយ៉ាងខ្លាំងនៃការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីនិងពហុភាគីទូទាំងសកលលោក បានកើនឡើងយ៉ាងខ្លាំងពីប្រមាណ ១០០ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ទៅជិត ៨០០ កិច្ចព្រមព្រៀងត្រឹមឆ្នាំ២០២២ (WTO ២០២២)។ ជាការចាំបាច់ យើងនឹងសិក្សាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសអភិវឌ្ឍន៍និងប្រទេសកំពុងអភិវឌ្ឍន៍ ដែលគ្របដណ្តប់លើបញ្ហាសេរីភាវូបនីយកម្មពាណិជ្ជកម្មនិងវិនិយោគ។ ការកើនឡើងនៃយ៉ាងឆាប់រហ័សនៃការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្តល់នូវកាលានុវត្តភាពនិងបញ្ហាប្រឈមដ៏សំខាន់ចំពោះយុទ្ធសាស្ត្របើកចំហនិងបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុកនិងតំបន់។ ឧទាហរណ៍ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) បាននិងកំពុងប្រើប្រាស់កិច្ចព្រមព្រៀង (ទ្វេភាគីនិងពហុភាគី) ដើម្បីបង្កើនច្រកចូលទីផ្សារនិងតំបន់និយម។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកំណត់ពីសកម្មភាពពាណិជ្ជកម្មស្របតាមមូលដ្ឋានច្បាប់ និងលក្ខខណ្ឌចាំបាច់សម្រាប់សមាហរណកម្មតំបន់តាមរយៈការចរចាពាណិជ្ជកម្ម។ ក្របខ័ណ្ឌសេរីភាវូបនីយកម្មពាណិជ្ជកម្មនិងវិនិយោគដែលកំណត់ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (ទ្វេភាគីនិងពហុភាគី) ផ្តល់នូវលក្ខខណ្ឌចាំបាច់សម្រាប់សមាហរណកម្មតំបន់ បរិវត្តកម្មរចនាសម្ព័ន្ធនៃប្រទេសជាសមាជិក និងយុទ្ធសាស្ត្រឆ្ពោះទៅមុខកាន់តែប្រសើរ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចតំបន់ទៅកាន់ជំហានបន្ទាប់ តួយ៉ាងកិច្ចព្រមព្រៀងវឌ្ឍនភាពនិងគ្រប់ជ្រុងជ្រោយសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) និង កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (អាសិប)។ ម្យ៉ាងវិញទៀត យើងត្រូវធ្វើការកែទម្រង់ និងបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក (តម្រូវការលក្ខខណ្ឌគ្រប់គ្រាន់) ដើម្បីទាញយកប្រយោជន៍ និងចាប់យកឱកាសជាអតិបរិមាពីក្របខ័ណ្ឌសមាហរណកម្មតំបន់ (លក្ខខណ្ឌគ្រប់គ្រាន់)ដែលផ្តល់ឱ្យដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ លក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានសមាហរណកម្មពេញលេញ

នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី តម្រូវឱ្យមានការចូលរួម និងបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចក្នុងស្រុក តួយ៉ាង ការចូលរួមពីក្រុមហ៊ុនក្នុងស្រុក សមត្ថភាពផលិតនិងការតភ្ជាប់ក្នុងស្រុកក្នុងវិស័យកម្មន្តសាល ការតភ្ជាប់សេវាកម្ម និងការកសាងស្ថាប័នឆ្ពោះទៅមុខ ដូចជា បច្ចេកវិទ្យា នវានុវត្តន៍ បញ្ញានិមិត្ត និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីសម្រួលពាណិជ្ជកម្មឆ្លងព្រំដែន។ មូលដ្ឋានគ្រឹះ ឬលក្ខខណ្ឌគ្រប់គ្រាន់ រួមជាមួយនឹងសមាហរណកម្ម សេដ្ឋកិច្ចក្នុងស្រុកគឺជាកត្តាចាំបាច់ក្នុងការអភិវឌ្ឍគោលនយោបាយឧស្សាហកម្មឱ្យស៊ីសង្វាក់នឹងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដើម្បីបង្កើនការបែងចែកធនធាននិងការកាត់បន្ថយហានិភ័យគោលនយោបាយនៃផែនការឧស្សាហកម្មប្រកបដោយប្រសិទ្ធភាព ការកាត់បន្ថយថ្លៃបរិវត្តកម្មរចនាសម្ព័ន្ធ និងការពង្រឹងធុរកិច្ចក្នុងការរៀបចំផែនការវិនិយោគឆ្ពោះទៅមុខនិងការទទួលយកបច្ចេកវិទ្យា ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីឆ្ពោះទៅមុខ មានសារសំខាន់ក្នុងការកំណត់ក្របខ័ណ្ឌចាំបាច់សម្រាប់សមាហរណកម្មតំបន់កាន់តែស៊ីជម្រៅ រួមមាន ការប្រែប្រួលបច្ចេកវិទ្យានិងនវានុវត្តន៍ ការបើកច្រកទីផ្សារ ជវភាពនៃខ្សែច្រវាក់តម្លៃផលិតកម្មសកល និងការរក្សាក្របខ័ណ្ឌពាណិជ្ជកម្មស្របតាមមូលដ្ឋានច្បាប់សម្រាប់ការអភិវឌ្ឍនាពេលអនាគត។ ឧទាហរណ៍ កិច្ចព្រមព្រៀងអាសិបមានសមាជិក ១៥ ប្រទេស ដែលកំណត់របៀបវារៈសម្រាប់សមាហរណកម្មតំបន់ និងបង្កើនច្រកចូលទីផ្សារសម្រាប់ពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវា និងការវិនិយោគ និង ដោះស្រាយបញ្ហាមិនមែនព្រំដែន។ កិច្ចព្រមព្រៀងអាសិប ក៏កំណត់របៀបវារៈសម្រាប់កិច្ចសហប្រតិបត្តិការតំបន់និងការកសាងស្ថាប័ន ដើម្បីពង្រឹងសមាហរណកម្មតំបន់អាស៊ីបូព៌ា។ កិច្ចព្រមព្រៀងអាសិបដែលជាកិច្ចព្រមព្រៀងរស់ អាចជួយដោះស្រាយបញ្ហាសំខាន់ថ្មីៗនាពេលអនាគត (Thangavelu et al. ២០២២)។ សមាជិកអាសិបដែលមានការអភិវឌ្ឍតិចតួចទទួលបានផលប្រយោជន៍ពី "វិធានការការពារ" អន្តរកាល និងប្រព្រឹត្តិកម្មដោយឡែកសម្រាប់ការប្តេជ្ញានៃការធ្វើពាណិជ្ជកម្មនិងវិនិយោគ។ ឧទាហរណ៍ ទំនិញដែលមានប្រភពដើមកំណើតពីសមាជិកដែលមានការអភិវឌ្ឍតិចតួចណាមួយមិនមែនជាកម្មវត្ថុដែលត្រូវទទួលរងវិធានការការពារពីសមាជិកអភិវឌ្ឍន៍ទេ[1] ហើយសមាជិកអភិវឌ្ឍន៍ដែលបានដាក់វិធានការការពារមិនត្រូវទាមទារសំណងការខូចខាតពីសមាជិកដែលមានការអភិវឌ្ឍតិចតួចដែលទទួលរងផលប៉ះពាល់ពីវិធានការការពារនោះទេ[2]។

ទោះបីជាវិសាលភាពនិងជម្រៅនៃសេរីភាវូបនីយកម្មមានភាពខុសគ្នាទៅតាមកិច្ចព្រមព្រៀងនីមួយៗ ដែលធ្វើឱ្យមានពិពិធភាពនៃរដ្ឋជាសមាជិកក៏ដោយ ក៏កិច្ចព្រមព្រៀងភាគច្រើនត្រូវបានគេរៀបចំឡើងក្នុងគោលបំណងបង្កើនច្រកចូលទីផ្សារតាមរយៈការកាត់បន្ថយពន្ធគយ និងការលុបបំបាត់របាំងមិនមែនព្រំដែនឱ្យកាន់តែទូលំទូលាយដោយការគ្រប់គ្រងការវិនិយោគផ្ទាល់ពីបរទេស ការការពារកម្មសិទ្ធិបញ្ញា ការរក្សាគោលនយោបាយប្រកួតប្រជែង និងការធ្វើសេរីភាវូបនីយកម្មសេវា (Baccini ២០១៩)។ ដូចនេះ គោលបំណងសំខាន់នៃគោលនយោបាយក្នុងស្រុកគឺការទាញយកប្រយោជន៍ជាអតិបរិមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីសម្រាប់ឧស្សាហកម្មនិងធុរកិច្ចក្នុងស្រុក។ ផ្ទុយទៅវិញ ថ្មីៗនេះ អ្នកចរចាពាណិជ្ជកម្មបានទទួលស្គាល់ថា ធុរជនក្នុងស្រុកពុំសូវបានប្រើប្រាស់កិច្ចព្រមព្រៀងទាំងនេះទេ។ ការសិក្សាថ្មីៗបានបង្ហាញថាការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតំបន់ដោយធុរជនមានអត្រាទាប ដោយមានតែក្រុមហ៊ុនធំៗប៉ុណ្ណោះប្រើប្រាស់ (Thangavelu, Narjoko, និង Urata ២០២១; Hayakawa and Shino ២០២១; Chia, ២០១០; Kawai និង Wignaraja ២០១១; Tambunan និង Chandra ២០១៤; Taratorn, Tassanee, និង Nuttawut ២០០៨)។ បញ្ហានេះបង្កើតជាសំណួរគោលនយោបាយដ៏សំខាន់អំពីឥទ្ធិពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីលើសកម្មភាពធុរកិច្ច និងគោលនយោបាយពាណិជ្ជកម្មទូទៅនៅកម្ពុជា។ អាស្រ័យហេតុនេះ អត្ថបទសង្ខេបគោលនយោបាយនេះ មានគោលបំណងសិក្សាពីក្របខ័ណ្ឌក្នុងការបង្កើនការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់កម្ពុជា។ អត្ថបទនេះ ក៏ផ្តល់នូវអនុសាសន៍គោលនយោបាយសំខាន់ៗ ដើម្បីទាញយកប្រយោជន៍ពីការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីសម្រាប់សេដ្ឋកិច្ចកម្ពុជា។

[1] កិច្ចព្រមព្រៀងអាសិប មាត្រា ៧.៦.២ ការនាំចូល De Minimis និង ប្រព្រឹត្តិកម្មពិសេស។

[2] ដដែល មាត្រា ៧.៧.៦។

## ២.ទន្ន្ធីករណ៍នៃការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី[3] ត្រូវបានកំណត់ដោយក្របខ័ណ្ឌឥរិយាបថ រចនាសម្ព័ន្ធ និងស្ថាប័ន នៃរចនាសម្ព័ន្ធឧស្សាហកម្មក្នុងស្រុក។ ទី១ ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតាមបែបឥរិយាបថ កំណត់ឥរិយាបថរបស់ក្រុមហ៊ុនក្នុងវិស័យផ្សេងៗ រួមទាំងមីក្រូក្រុមហ៊ុន ក្រុមហ៊ុនតូច មធ្យម និងធំ ដែលអ្នកនាំចេញនិងអ្នកនាំចូលមានឥរិយាបថផ្សេងៗគ្នាចំពោះពាណិជ្ជកម្មនិងការវិនិយោគតំបន់និងសកល។ ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីខុសគ្នាអាស្រ័យលើលក្ខណៈនៃក្រុមហ៊ុននិងការស្វែងយល់របស់ក្រុមហ៊ុនចំពោះ អត្ថិភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ទី២ ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតាមបែបរចនាសម្ព័ន្ធបង្ហាញពីបញ្ហារចនាសម្ព័ន្ធចំពោះថ្លៃចំណាយប្រតិបត្តិការនិងលិខិតស្នាមខ្ពស់ និងអនុលោមភាពខ្ពស់។ ឧទាហរណ៍ ភាគីនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មត្រូវអនុលោមតាមតម្រូវការសំខាន់ៗនិងវិធានការរដ្ឋបាល ដើម្បីបញ្ជាក់ពីប្រភពដើមកំណើតទំនិញក្នុងការទទួលបានអត្ថប្រយោជន៍ពីពន្ធអនុគ្រោះ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រួតគ្នានឹងបង្កើនថ្លៃចំណាយប្រតិបត្តិការនៃការចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនោះ (Thangavelu, Narjoko, និង Urata ២០២១; Hayakawa និង Shiino ២០២១)។ វិធានដើមកំណើតទំនិញកាន់តែរឹតត្បិតធ្វើឱ្យធុរជនពិចារណាលើការប្រើប្រាស់ពន្ធគយ "ប្រជាជាតិដែលមានការអនុគ្រោះបំផុត" (MFN) ជំនួសវិញ (Kasteng និង Inama ២០១៨)។ ចុងក្រោយ ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីតាមបែបស្ថាប័ន គួរតែមានការជួយសម្រួលពីស្ថាប័នដោយមិនត្រូវដាក់បញ្ញត្តិ ទៅតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនីមួយៗ រួមមាន ការធ្វើសាមញ្ញកម្មនីតិវិធីនាំចេញ និងពង្រឹងប្រព័ន្ធបញ្ជរតែមួយជាតិ និងការធ្វើសមាហរណកម្មជាមួយប្រព័ន្ធបញ្ជរតែមួយអាស៊ាន (Thangavelu, Narjoko, និង Urata ២០២១; Hayakawa និង Shiino ២០២១)។

ខណៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រូវបានបង្កើតយ៉ាងឆាប់រហ័សនាប៉ុន្មានទសវត្សរ៍មកនេះ ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅតែជាប្រធានបទក្តៅក្នុងចំណោមអ្នកគោលនយោបាយពាណិជ្ជកម្ម និងអ្នកស្រាវជ្រាវគោលនយោបាយ។ ការសិក្សាថ្មីៗ បានបង្ហាញពីឥទ្ធិពលសិក្សា (learning effects) (Hayakawa និង Shiino ២០២១; Kawai និង Wignaraja ២០១១), ឥទ្ធិពលម៉ារជីន (margin effects) ឥទ្ធិពលមាត្រដ្ឋាន (scale effects) និងឥទ្ធិពលវិធានដើមកំណើតទំនិញ (rules of origin effects) (Hayakawa, Kim, និង Lee ២០១៤) គឺជាធាតុសំខាន់ដើម្បីកំណត់ការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ Hayakawa និង Shiino (២០២១) ព្រមទាំង Kawai និង Wignaraja (២០១១) បង្ហាញថា អត្រាប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីបានកើនឡើងតាមរយៈ "ឥទ្ធិពលសិក្សា" ដែលតាមរយៈដំណើរការសិក្សា ក្រុមហ៊ុនចំណាយពេលវេលាច្រើនក្នុងការសិក្សាពីទីផ្សារនាំចេញ និងទាញយកប្រយោជន៍ពីការអនុគ្រោះថ្មីៗនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ការសិក្សាផ្សេងទៀតបានរកឃើញថា ការកើនឡើងនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក៏ដូចជាការកាត់បន្ថយជាបន្តបន្ទាប់នៃម៉ារជីនអនុគ្រោះ មានហេតុផលសមរម្យនិងសំខាន់ចំពោះអត្រាប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទាបនៅតំបន់អាស៊ីបូព៌ា តួយ៉ាង ក្រុមហ៊ុនជប៉ុនតិចតួចណាស់ដែលប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជប៉ុន-សិង្ហបុរី ដោយសារតែអត្រាពន្ធ MFN របស់សិង្ហបុរីទាបស្ទើរស្មើសូន្យទៅហើយ (Takahashi និង Urata ២០១០)។

ការសិក្សាថ្មីៗផ្សេងទៀត បានប្រើប្រាស់ទិន្នន័យកម្រិតគយលើកម្រិតផលិតផលនិងកម្រិតក្រុមហ៊ុន ដើម្បីធ្វើការសិក្សាពីឥទ្ធិពលនៃម៉ារជីនអនុគ្រោះលើការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ក្នុងចំណោមការសិក្សានេះ Hayakawa, Nuttawut, និង Yoshimi (២០២១) បានរកឃើញគម្លាតអត្រាពន្ធអនុគ្រោះកាន់តែធំរវាងអត្រាពន្ធ MFN និងអត្រាពន្ធអនុគ្រោះនៃកិច្ចព្រមព្រៀង

[3] Kasteng និង Inama (២០១៨) បង្ហាញសូចនាករចម្បងពីរដើម្បីគណនាការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ សូចនាករទី១ គឺ "អត្រាប្រើប្រាស់ពន្ធអនុគ្រោះ" ដែលគណនាផ្អែកលើ "តម្លៃនៃពន្ធអនុគ្រោះដែលបានប្រើប្រាស់" និង "តម្លៃនៃពន្ធអនុគ្រោះដែលមិនប្រើប្រាស់"។ សូចនាករទី២ គឺ "អត្រាចំណេញពន្ធអនុគ្រោះ" ដែលគណនាផ្អែកលើ "តម្លៃនៃការចំណេញពន្ធអនុគ្រោះ" និង "តម្លៃនៃថ្លៃពន្ធអនុគ្រោះ"។ លើសពីនេះ អ្នកនិពន្ធក៏បានស្នើសូចនាករអមពីរបន្ថែមទៀត ដើម្បីគណនាអត្ថប្រយោជន៍និងថ្លៃនៃការប្រើប្រាស់ពន្ធអនុគ្រោះ រួមមាន "ម៉ារជីនអនុគ្រោះមធ្យមនៃការអនុគ្រោះដែលបានប្រើប្រាស់" និង "ម៉ារជីនអនុគ្រោះមធ្យមនៃការអនុគ្រោះដែលមិនប្រើប្រាស់"។

ពាណិជ្ជកម្មសេរី ដែលមានឥទ្ធិពលវិជ្ជមានលើអត្រាប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ការសិក្សាផ្សេងៗទៀត ក៏ពន្យល់ពីឥទ្ធិពលវិជ្ជមាននៃការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅតំបន់អាស៊ីនិងអាស៊ាន។ ឧទាហរណ៍ ឥទ្ធិពលវិជ្ជមានត្រូវបានរកឃើញចំពោះក្រុមហ៊ុនតៃវ៉ាន់ដែលនាំចូលក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចិន-កោះតៃវ៉ាន់ (Chang និង Hayakawa ២០១៤) ចំពោះការនាំចូលរបស់កូរ៉េក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (Hayakawa, Kim, និង Lee ២០១៤) និងចំពោះការនាំចូលរបស់ជប៉ុនក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជប៉ុន (Hayakawa និង Shiino, ២០២១)។ ម្យ៉ាងវិញទៀត ឥទ្ធិពល ម៉ារជីនលើអត្រាប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីខុសគ្នាច្រើនទៅតាមប្រទេសនាំចូលនីមួយៗ។ ឧទាហរណ៍ Hayakawa, Kim, និង Lee (២០១៤) បង្ហាញថាមេគុណនៃឥទ្ធិពលម៉ារជីនមានប្រហែល ០,០១ នៅកូរ៉េ ខណៈ Keck និង Lendle (២០១២) រកឃើញ ០,១ នៅសហរដ្ឋអាម៉េរិក ១,១ នៅកាណាដា និងប្រហែល ២,៥ នៅអូស្ត្រាលី។ ការសិក្សាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) ដោយ Thangavelu, Narjoko, និង Urata (២០២១) បង្ហាញពីគម្លាតពន្ធអនុគ្រោះវិជ្ជមានចំពោះសមាជិកអាស៊ានក្នុងកិច្ចព្រមព្រៀង AANZFTA បន្ទាប់ពីគណនាឥទ្ធិពលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រួតគ្នា។

ឥទ្ធិពលមាត្រដ្ឋាន គឺជាឥទ្ធិពលដែលកើតចេញពីបរិមាណច្រើននៃការនាំចូលក្នុងវិស័យជាក់លាក់ស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនីមួយៗ។ ការសិក្សាភាគច្រើនបង្ហាញថា ឥទ្ធិពលមាត្រដ្ឋានមានផលវិជ្ជមាន ប៉ុន្តែខុសគ្នាទៅតាមសេដ្ឋកិច្ចនាំចូលចន្លោះពី ០,០៣ ទៅ ០,០៧ (Keck និង Lendle ២០១២; Hayakawa, Kim, និង Lee ២០១៤)។ លើសពីនេះ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីត្រួតគ្នា (ឥទ្ធិពល "Spaghetti Bowl") មានទំនោរបង្កើនថ្លៃចំណាយប្រតិបត្តិការ និងព័ត៌មានទៅតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនីមួយៗ និងថ្លៃដើម (entry cost) ក្នុងការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដោយមានតែក្រុមហ៊ុនធំៗប៉ុណ្ណោះប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (Thangavelu, Narjoko, និង Urata ២០២១)។

ខុសពីលក្ខណៈទូទៅនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី Kasteng និង Inama (២០១៨) បង្ហាញថាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីសហភាពអឺរ៉ុបមានសារសំខាន់តិចតួច ខណៈដែលក្រុមហ៊ុនជាច្រើនសុខចិត្តបង់ពន្ធគយខ្ពស់ ដោយមិនទាញយកប្រយោជន៍ពីការអនុគ្រោះពន្ធនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនោះទេ។ ដូចនេះ ការអនុគ្រោះពន្ធគយមិនបង្ហាញជាចាំបាច់ពីចលនាទំនិញឆ្លងព្រំដែន ដោយសារការចំណាយរដ្ឋបាលនិងអនុលោមភាពខ្ពស់ តម្លៃនៃការនាំចេញ និងផលចំណេញដោយសារការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ បន្ថែមលើនេះទៀត យោងតាមការស្ទង់មតិនិងការប្រើប្រាស់ទិន្នន័យគយ Taratorn, Tassanee, និង Nuttawut (២០០៨) បានបង្ហាញថាកង្វះព័ត៌មានពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គឺជាកត្តាសំខាន់ធ្វើឱ្យអត្រាប្រើប្រាស់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅប្រទេសថៃមានកម្រិតទាប ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ការសិក្សាជាច្រើនបានផ្តោតការយកចិត្តទុកដាក់លើឥទ្ធិពលវិធានដើមកំណើតទំនិញដោយជឿថា វិធានដើមកំណើតទំនិញកាន់តែរឹតត្បិត នឹងកាត់បន្ថយការប្រើប្រាស់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ ក្នុងចំណោមការសិក្សាទាំងនេះ Kaufmann (២០១៤) ព្រមទាំង Keck និង Lendle (២០១២) បានរកឃើញឥទ្ធិពលអវិជ្ជមាននៃវិធានដើមកំណើតទំនិញ។ ដោយធ្វើវិត្តារកម្មការសិក្សានេះ Hayakawa និង Nuttawut (២០១៧) បានរកឃើញថា ការធ្វើសុខដុមនីយកម្មវិធានដើមកំណើតទំនិញតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗគ្នា អាចកាត់បន្ថយថ្លៃចំណាយ និង បង្កើនអត្រាប្រើប្រាស់កិច្ចព្រមព្រៀងបន្ថែមទៀត។

យ៉ាងណាក៏ដោយ ក៏ការសិក្សាមួយចំនួនបានបង្ហាញពីផលវិជ្ជមាននៃកិច្ចព្រមព្រៀងពាណិជ្ជសេរី។ ការសិក្សាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរបស់អូស្ត្រាលីដោយ PwC (២០១៨) បានបង្ហាញថាការទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ លើសពីការធ្វើពាណិជ្ជកម្មទំនិញទៅទៀត។ ក្រុមហ៊ុនរបស់អូស្ត្រាលីដែលធ្វើពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវា និងវិនិយោគសុទ្ធតែទទួលបានផលប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ។ ព្រមជាមួយសកម្មភាពពាណិជ្ជកម្មស្របតាមមូលដ្ឋានច្បាប់ច្បាស់លាស់

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្ដល់នូវយុទ្ធសាស្ត្រឆ្ពោះទៅមុខក្នុងការចូលរួមសកម្មភាពពាណិជ្ជកម្មនិងវិនិយោគក្នុងតំបន់ ដែលនាំឱ្យមានការកើនឡើងសកម្មភាពខ្សែប្រវាក់តម្លៃសកល។

ការសិក្សាថ្មីមួយដោយ Thangavelu, Narjoko, និង Urata (២០២១) បានវិភាគពីឥទ្ធិពលនៃកិច្ចព្រមព្រៀង AANZFTA លើពាណិជ្ជកម្មអូស្ត្រាលី ពិសេសការនាំចូលពីប្រទេសអាស៊ានទាំងដប់ ដោយប្រើប្រាស់ទិន្នន័យគយចំណាត់ថ្នាក់ ៦ខ្ទង់ ពីឆ្នាំ២០១២-២០១៦។ ការសិក្សានេះ ក៏បានគណនាភាពត្រួតគ្នានៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីដែលអាចនឹងមានឥទ្ធិពលលើកិច្ចព្រមព្រៀង AANZFTA។ លទ្ធផល បានបង្ហាញពីផលវិជ្ជមាននៃការអនុគ្រោះពន្ធលើកិច្ចព្រមព្រៀងនេះ។ យ៉ាងណាក៏ដោយ លទ្ធផលបានបង្ហាញពីអត្រាទាបនៃការទាញប្រយោជន៍ពីកិច្ចព្រមព្រៀងនេះពីបណ្ដាប្រទេសអាស៊ានបើប្រៀបធៀបនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងអូស្ត្រាលីនិងម៉ាឡេស៊ី, ថៃ, និងសិង្ហបុរី។ ការសិក្សាក៏បានរកឃើញនូវផលវិជ្ជមាននៃវិធានដើមកំណើតទំនិញជម្រើស (co-sharing) លើការទាញប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ។

## ៣.ការប្រើប្រាស់កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយអាស៊ាន-ជប៉ុន៖ ទស្សនៈពីកម្ពុជា

បច្ចុប្បន្ននេះ កម្ពុជាបាននិងកំពុងចូលជាសមាជិកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាច្រើន។ ក្នុងនាមជាសមាជិកអាស៊ាន កម្ពុជាបានក្លាយជាសមាជិកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA) កិច្ចព្រមព្រៀងពាណិជ្ជកម្មអាស៊ានបូកមួយ (តួយ៉ាង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) អាស៊ាន-ចិន (ACFTA) អាស៊ាន-ហុងកុង (AHKFTA បានចុះហត្ថលេខាឆ្នាំ២០១៧) អាស៊ាន-ឥណ្ឌា (AIFTA) អាស៊ាន-ជប៉ុន (AJCEP) អាស៊ាន-កូរ៉េ (AKFTA)) និងអាសិប (ចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២)។ ក្រៅពីនេះ កម្ពុជាក៏បានបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីជាមួយចិន (CCFTA) ដែលបានចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ និងជាមួយកូរ៉េ (CKFTA) បានចូលធរមាននៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២២។ កម្ពុជាក៏បាននិងកំពុងធ្វើការចរចាយ៉ាងសកម្មនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗទៀត ដូចជាកិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម (Cam-UAE CEPA) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ប៉ាគីស្ថាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ុបអាស៊ី (EAEU)។ ក្រៅពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជាក៏ទទួលបាននូវការអនុគ្រោះពន្ធជាច្រើនទៀតពីប្រទេសអភិវឌ្ឍន៍និងកំពុងអភិវឌ្ឍន៍ដូចជាអាម៉េរិក[4] ជប៉ុន សហភាពអឺរ៉ុប និងប្រទេសអភិវឌ្ឍន៍ដទៃទៀត។ អត្ថបទសង្ខេបគោលនយោបាយនេះនឹងសិក្សាពីការទាញយកប្រយោជន៍ពីកិច្ចព្រមព្រៀង AJCEP ដោយផ្ដោតលើការនាំចូលទំនិញរបស់ជប៉ុនពីកម្ពុជា។

កិច្ចព្រមព្រៀង AJCEP[5] គឺជាកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយដែលរួមបញ្ចូលនូវសេរីភាវូបនីយកម្មទំនិញនិងសេវា ការវិនិយោគ វិធានដើមកំណើតទំនិញ អនាម័យនិងភូតគាមអនាម័យ របាំងបច្ចេកទេសពាណិជ្ជកម្ម យន្តការដោះស្រាយវិវាទ និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច។ កិច្ចព្រមព្រៀង AJCEP បានចាប់ផ្ដើមការចរចានៅខែមេសា ឆ្នាំ២០០៥ និងបានចុះហត្ថលេខានៅខែមេសា ឆ្នាំ

[4] ប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់សហរដ្ឋអាម៉េរិកសម្រាប់កម្ពុជាត្រូវបានព្យួរកាលពីចុងឆ្នាំ២០២០ (May ២០២១).

[5] កិច្ចព្រមព្រៀង AJCEP ត្រូវបានធ្វើវិសោធនកម្មដោយ "ពិធីសារទី១ ស្ដីពី ការធ្វើវិសោធនកម្មកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងជប៉ុន និងប្រទេសសមាជិកអាស៊ាន" ដែលបានចុះហត្ថលេខាដោយប្រទេសជប៉ុន ខែកុម្ភៈ ឆ្នាំ២០១៩ និងដោយប្រទេសសមាជិកអាស៊ានក្នុងខែមីនានិងមេសា (Ministry of Foreign Affairs of Japan ២០២០)។ ពិធីសារទី១ស្ដីពីការធ្វើវិសោធនកម្មកិច្ចព្រមព្រៀង AJCEP បានចូលជាធរមាន នៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ រួមមានជប៉ុន ឡាវ មីយ៉ាន់ម៉ា សិង្ហបុរី ថៃ និងវៀតណាម និងប្រទេសសមាជិកអាស៊ានដទៃទៀតនៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២។ ពិធីសារនេះបន្ថែមបញ្ញត្តិពាក់ព័ន្ធនឹងសេរីភាវូបនីយកម្មពាណិជ្ជកម្មសេវា ការចល័តរូបវន្តបុគ្គល និងការវិនិយោគលើកិច្ចព្រមព្រៀង AJCEP។ ពិធីសារនេះ គឺជាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទី១ ស្ដីពីពាណិជ្ជកម្មសេវានិងការចល័តរូបវន្តបុគ្គលទាក់ទងនឹងកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា។ ពិធីសារនេះ ក៏មានរួមបញ្ចូលការប្ដេជ្ញាចិត្តរបស់ប្រទេសសមាជិកអាស៊ានលើវិធានគតិយុត្តនិងសេរីភាវូបនីយកម្មដែលមិនបានបញ្ចូលក្នុងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទ្វេភាគី និងកិច្ចព្រមព្រៀងពាក់ព័ន្ធដែលចុះហត្ថលេខារវាងជប៉ុននិងប្រទេសសមាជិកអាស៊ាននីមួយៗ។

២០០៨[6]។ កិច្ចព្រមព្រៀងនេះបានចូលជាធរមាននៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៨ សម្រាប់ជប៉ុន ឡាវ មីយ៉ាន់ម៉ា សឹង្ហបុរី និងវៀតណាម ថ្ងៃទី០១ ខែមករា ឆ្នាំ២០០៩ សម្រាប់ព្រុយណេ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៩ សម្រាប់ម៉ាឡេស៊ី ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៩ សម្រាប់ថៃ និងថ្ងៃទី០១ ខែមករា ឆ្នាំ២០១០ សម្រាប់កម្ពុជា។

កិច្ចព្រមព្រៀង AJCEP បានផ្តល់ប្រយោជន៍ជាច្រើនដល់រដ្ឋជាសមាជិកអាស៊ាន។ ក្រោយកិច្ចព្រមព្រៀង AJCEP ចូលជាធរមាន កម្ពុជាអាចនាំចេញទំនិញទៅជប៉ុនក្នុងអត្រាពន្ធសូន្យភ្លាមៗ ប្រមាណ ៩០% នៃបន្ទាត់ពន្ធគយសរុប និងទទួលបានការអនុគ្រោះប្រមាណ ៣% នៃបន្ទាត់ពន្ធគយបន្ថែមទៀតក្នុងរយៈពេល១០ឆ្នាំ ខណៈដែល ព្រុយណេ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ ផ្តល់ឱ្យកម្ពុជានូវការលុបបំបាត់ ឬកាត់បន្ថយអត្រាពន្ធជាដំណាក់កាលប្រហែល ៩០% នៃបន្ទាត់ពន្ធគយសរុបក្នុងរយៈពេល១០ឆ្នាំ វៀតណាមក្នុងរយៈពេល១៥ឆ្នាំ ដោយឡែក ឡាវ និងមីយ៉ាន់ម៉ា នឹងលើកលែងពន្ធប្រមាណ៨៥%នៃបន្ទាត់ពន្ធគយសរុបក្នុងរយៈពេល១៨ឆ្នាំ (Kagami ២០១១)។ លើសពីនេះ កិច្ចព្រមព្រៀង AJCEP អនុញ្ញាតឱ្យសមាជិកអាចដឹកជញ្ជូនទំនិញដែលនឹងត្រូវនាំចេញទៅវិញដោយប្រើវិធានដើមកំណើតទំនិញបន្ត (back-to-back) ក្នុងចំណោមប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀង តួយ៉ាង ទំនិញដែលមានដើមកំណើតពីប្រទេសជាសមាជិកកិច្ចព្រមព្រៀង AJCEP នាំចូលមកកម្ពុជា អាចត្រូវបាននាំចេញទៅវិញក្នុងចំណោមប្រទេសជាសមាជិកដោយទទួលបាននូវភាពអនុគ្រោះពន្ធ ក្នុងលក្ខខណ្ឌទំនិញទាំងនោះមិនត្រូវបានកែច្នៃបន្ថែមណាមួយនៅកម្ពុជា ដោយរក្សានូវលក្ខណៈដើមទំនិញ។ ទំនិញដែលមានដើមកំណើតពីប្រទេសជាសមាជិកកិច្ចព្រមព្រៀង AJCEP ដែលត្រូវនាំចេញ និងដឹកជញ្ជូនឆ្លងកាត់ប្រទេសជាសមាជិកដទៃទៀត ត្រូវរក្សាស្ថានភាពដើមនៃទំនិញទាំងនោះឱ្យនៅដដែល។ កិច្ចព្រមព្រៀងនេះ ក៏អនុញ្ញាតឱ្យមានការចេញវិក្កយបត្រទំនិញដោយប្រទេសទីបីផងដែរ តួយ៉ាង អាជ្ញាធរគយនៃប្រទេសនាំចូលអាចទទួលយកវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ នៅពេលដែលវិក្កយបត្រលក់ត្រូវបានចេញដោយប្រទេសមួយផ្សេងទៀត ឬក្រុមហ៊ុននាំចេញទំនិញដើម្បីបម្រើឱ្យវិស័យផ្សេងៗទៀត ដែលទំនិញទាំងនោះសមស្របតាមលក្ខខណ្ឌតម្រូវ។ វិក្កយបត្រនេះអាចត្រូវបានចេញដោយប្រទេសដែលមិនមែនជាភាគីនៃកិច្ចព្រមព្រៀង AJCEP។ បន្ថែមពីនេះទៅទៀត កិច្ចព្រមព្រៀង AJCEP ក៏អនុញ្ញាតឱ្យមានវិធានបូកបន្ថែមតំបន់ តួយ៉ាង វត្ថុធាតុដើមដែលមានដើមកំណើតពីប្រទេសសមាជិកកិច្ចព្រមព្រៀង AJCEP ត្រូវបានយកមកពិចារណានិងវាយតម្លៃលក្ខណៈវិនិច្ឆ័យដើមកំណើតនៃផលិតផលសម្រេច ត្រូវបានផលិតនៅកម្ពុជា។

កិច្ចព្រមព្រៀង AJCEP ក៏បានដាក់ចេញនូវកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់វិធានដើមកំណើតទំនិញ ដែលពាណិជ្ជករឆ្លងព្រំដែនអាចមានភាពបត់បែនក្នុងការជ្រើសរើសវិធានដើមកំណើតទំនិញ ដើម្បីទាញយកប្រយោជន៍ពីប្រព្រឹត្តិកម្មអនុគ្រោះពន្ធនេះ។ តារាងទី១ បង្ហាញចំនួនវិធានដើមកំណើតទំនិញដែលត្រូវប្រើប្រាស់ក្រោមកិច្ចព្រមព្រៀង AJCEP ធៀបនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានដទៃទៀត។ វិធានផ្លាស់ប្តូរចំណាត់ថ្នាក់តាមតារាងពន្ធគយ (ក្នុងកំរិត២ខ្ទង់, ៤ខ្ទង់, និង៦ខ្ទង់) គឺជាវិធានទូទៅនៃកិច្ចព្រមព្រៀង AJCEP ខណៈដែលវិធានដើមកំណើតទំនិញផ្អែកលើសមាសភាគតម្លៃតំបន់ RVC ត្រូវបានប្រើជាវិធានជម្រើស។ វិធានដើមកំណើតទំនិញនានានៃកិច្ចព្រមព្រៀង AJCEP មានកម្រិតរឹតត្បិតទាបជាងកិច្ចព្រមព្រៀង AIFTA ប៉ុន្តែមានការរឹតត្បិតខ្លាំងជាងកិច្ចព្រមព្រៀង ATIGA និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន+១ ផ្សេងៗទៀត។ នៅក្រោមកិច្ចព្រមព្រៀង AJCEP ទំនិញចំនួន ១.៧៥៣មុខ ស្ថិតក្នុងផលិតផលផ្លាស់ប្តូរបន្ទាត់ពន្ធគយ ៦ខ្ទង់ ប្រមាណ ៣៤% ប្រឈមនឹងការរឹតត្បិតនៃវិធានដើមកំណើតទំនិញ (តួយ៉ាង វិធានផ្លាស់ប្តូរបន្ទាត់ពន្ធគយ២ខ្ទង់ CC) ខណៈដែលទំនិញប្រហែល ៣.០៧៧ មុខផ្សេងទៀតនឹងទទួលបានការរិតត្បិតទាបជាង (តួយ៉ាង វិធានជម្រើសស្មើភាពគ្នា co-equal sharing rules) ដែលត្រូវបានប្រើក្នុងវិធានផ្លាស់ប្តូរបន្ទាត់ពន្ធគយ ៦ខ្ទង់/សមាសភាគតម្លៃតំបន់ (CTH/RVC)។

[6] ការចរចាត្រូវបានផ្តួចផ្តើមឡើងដោយសេចក្តីប្រកាសរួមរបស់មេដឹកនាំអាស៊ាននិងជប៉ុនស្តីពី ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ ដែលបានចុះហត្ថលេខានៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០២ នៅរាជធានីភ្នំពេញ និង ដោយក្របខ័ណ្ឌស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាននិងជប៉ុន ដែលបានចុះហត្ថលេខានៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៣ នៅកោះបាលី។

**តារាងទី១៖ វិធានដើមកំណើតទំនិញតាមក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅកម្រិតចំណាត់ថ្នាក់ផលិតផល ៦ខ្ទង់**

| ប្រភេទនៃវិធានដើមកំណើតទំនិញ | AJCEP | AANZ | ACFTA | ATIGA | AIFTA | AKFTA |
|---|---|---|---|---|---|---|
| CC | ១០៧៩ | ២៤៧ | ១ | - | - | ៥ |
| CC&RVC | ២ | - | - | - | - | - |
| CC&SP | ៤០០ | ៣៧ | - | - | - | - |
| CC/( RVC&SP ) | - | ២០០ | - | - | - | - |
| CC/RVC | ១២២ | ៦០៦ | ៨ | ៣៤០ | - | ៥២៤ |
| CC/RVC/SP | - | ៣៥ | - | ១៧១ | - | - |
| CC/SP | - | ១៣ | - | - | - | - |
| CH | ១៥២ | ១១៧ | - | - | - | ១១ |
| CH&RVC | ៥ | - | - | - | - | - |
| CH&SP | ២៦៤ | - | - | - | - | - |
| CH/( CS&RVC )/RVC | - | ១៩៧ | - | - | - | - |
| CH/( RVC&SP ) | - | ៦ | - | - | - | - |
| CH/RVC | ២៩២១ | ២១៥១ | ១១៣ | ៤២៣២ | - | ៣៨៨០ |
| CH/RVC/SP | - | ២៣ | - | ៣២៧ | - | ២១ |
| CH/SP | - | ៨៦ | - | - | - | - |
| CS | ៧ | - | - | - | - | - |
| CS&RVC | - | ៣ | - | - | ៥២០៤ | - |
| CS/RVC | ៣៤ | ១០៣៧ | - | ១២៩ | - | ៧៤ |
| RVC | ២២២ | ៦៨ | ៤៦៨២ | - | - | ៧៥ |
| RVC/SP | - | - | ៣៩២ | ១ | - | - |
| SP | - | ៧០ | - | - | - | - |
| WO | ៣ | ៣០០ | ៨ | ៤ | - | ៦០៧ |
| WO/SP | - | ៨ | - | - | - | - |
| សរុប | ៥២១១ | ៥២០៤ | ៥២០៤ | ៥២០៤ | ៥២០៤ | ៥១៩៧ |

*សំគាល់៖ "CC" "CTH" និង "CTSH" គឺវិធានផ្លាស់ប្តូរជំពូក ផ្លាស់ប្តូរទីតាំង និងផ្លាស់ប្តូរអនុទីតាំង។ "WO" និង "RVC" គឺជាវិធានដែលបានកកើត ឬផលិតទាំងស្រុង និងសមាសភាគតម្លៃតំបន់។ "SPR" គឺជាវិធានដំណើរការជាក់លាក់មួយ។ "&" និង "/" បង្ហាញពីវិធានដែលតម្រូវឱ្យប្រកាន់ខ្ជាប់នូវវិធានទាំងពីរ និងវិធានទីមួយៗរៀងៗខ្លួន*

ប្រភព៖ Hayakawa, Nuttawut, និង Yoshimi ( ២០២១, តារាងទី២ )

គេសង្កេតឃើញថា ពាណិជ្ជកម្មទ្វេភាគីរបស់កម្ពុជាជាមួយភាគីនៃកិច្ចព្រមព្រៀង AJCEP កើនឡើងគួរឱ្យកត់សម្គាល់ចាប់តាំងពីកិច្ចព្រមព្រៀងនេះចូលជាធរមាន។ រូបភាពទី១ បង្ហាញពីនិន្នាការពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងភាគីនៃកិច្ចព្រមព្រៀង AJCEP។ តួលេខនេះ បង្ហាញថា ពាណិជ្ជកម្មទ្វេភាគីរបស់កម្ពុជាជាមួយសមាជិកអាស៊ានមានប្រមាណ ៨៨,៥៥% គឺប្រហែល ៣,២៨ ប៊ីលានដុល្លារ ក្នុងឆ្នាំ២០១៣ និងប្រមាណ ៨៩,០៥% ប្រហែល ១៤,១០ ប៊ីលានដុល្លារ នៅឆ្នាំ២០២១ ជាមួយនឹង

កំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ២០,១០%។ ពាណិជ្ជកម្មទ្វេភាគីរបស់កម្ពុជាជាមួយជប៉ុនបានកើនឡើងពី ៤២៤,០១ លានដុល្លារ ក្នុងឆ្នាំ២០១២ ដល់ ១,៧៣ ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២១ ដែលមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ១៨,៧៩% ខណៈអត្រាកំណើនជាមធ្យមប្រចាំឆ្នាំនៃការនាំចេញនិងនាំចូលមានប្រមាណ ២៤,៦៥% និង១៥,៣៥% រៀងគ្នា។

រូបភាពទី១៖ ពាណិជ្ជកម្មកម្ពុជាជាមួយសមាជិកកិច្ចព្រមព្រៀង AJCEP




ប្រភព៖ ITC Trade Map (International Trade Centre ២០២២)

តារាងទី២ បង្ហាញពីការនាំចូលនិងនាំចេញរបស់កម្ពុជាជាមួយជប៉ុនដោយចំណាត់ថ្នាក់ផលិតផល ២ ខ្ទង់ ក្នុងឆ្នាំ២០២១។ កម្ពុជានាំចេញជាចម្បងនូវផលិតផលវាយនភណ្ឌនិងស្បែក (៨០៦ លានដុល្លារ ស្មើនឹង ៧៤% រួមមានជំពូកទំនិញ ៤២ ៦១ ៦២ និង៦៣) ផលិតផលគ្រឿងម៉ាស៊ីននិងដឹកជញ្ជូន (១៣៨ លានដុល្លារ ស្មើនឹង ១៣% រួមមានជំពូកទំនិញ ៨៥ និង៨៥) និងផលិតផលស្បែកជើង (១១៣ លានដុល្លារ ស្មើនឹង១០% រួមមានជំពូកទំនិញ ៦៤ និង៦៦) ជាមួយនឹងអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ ២៥%, ៤១៨% និង ១៥% រៀងគ្នា ចាប់តាំងពីឆ្នាំ២០១២។ ការនាំចូលសំខាន់ៗរបស់កម្ពុជាមានដូចជា ផលិតផលគ្រឿងម៉ាស៊ីននិងដឹកជញ្ជូន (៤៦៤ លានដុល្លារ ស្មើនឹង៧២% រួមមានជំពូកទំនិញ ៨៤ ៨៥ និង៨៧) ផលិតផលវាយនភណ្ឌនិងស្បែក (៣២ លានដុល្លារ ស្មើនឹង៥% រួមមានជំពូកទំនិញ ៤១ ៥៥ និង៦៣) និងផលិតផលដែលទទួលបានពីថ្ម កញ្ចក់ និងលោហៈ (២៤លានដុល្លារ ស្មើនឹង ៤% រួមមានជំពូកទំនិញ ៦៩ និង៧៣) ជាមួយនឹងអត្រាកំណើនប្រចាំឆ្នាំ១៥%, ១៩% និង ៦៥% រៀងគ្នាចាប់តាំងពីឆ្នាំ២០១២។

ទោះបីជាពាណិជ្ជកម្មរវាងកម្ពុជានិងជប៉ុនត្រូវបានគេមើលឃើញថាមានការកើនឡើងក៏ដោយ ក៏ការរួមចំណែកនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីចំពោះកំណើនពាណិជ្ជកម្មនេះនៅតែជាចម្ងល់។ ដូចនេះ គោលនយោបាយសង្ខេបនេះមានគោលបំណងសិក្សាពីអត្រាប្រើប្រាស់កិច្ចព្រមព្រៀង AJCEP របស់កម្ពុជា។ អត្រាប្រើប្រាស់ត្រូវបានគណនាដោយប្រើក្របខ័ណ្ឌរបស់ Hayakawa និង Shino (២០២១) និង Thangavelu, Narjoko, និង Urata (២០២១)។

### តារាងទី២៖ ទំនិញអាទិភាពទាំង ១០ ដោយចំណាត់ថ្នាក់ផលិតផល ២ ខ្ទង់ នៃពាណិជ្ជកម្មកម្ពុជាជាមួយជប៉ុនក្នុងឆ្នាំ ២០២១ (គិតជាលានដុល្លារ)

| ការនាំចូល | | | | ការនាំចេញ | | | |
|---|---|---|---|---|---|---|---|
| ជំពូកទំនិញ | ទំហំពាណិជ្ជកម្ម | ចំណែក | កំណើន (២០១២-២១) | ជំពូកទំនិញ | ទំហំពាណិជ្ជកម្ម | ចំណែក | កំណើន (២០១២-២១) |
| ៨៧ | ៣៥៤.៥០ | ៥៥,៣៥% | ១៩,០០% | ៦១ | ៣៧២.១៨ | ៣៤,០៣% | ១៨,០០% |
| ៨៤ | ៧៦.០៩ | ១១,៨៨% | ៨,០០% | ៦២ | ៣៦៥.៥១ | ៣៣,៤២% | ៣៣,៤២% |
| ៨៥ | ៣៣.២០ | ៥,១៨% | ៣០,០០% | ៨៥ | ១២៨.៤៥ | ១១,៧៥% | ៤៣៩,០០% |
| ៣៩ | ២២.២៨ | ៣,៤៨% | ១៤២,០០% | ៦៤ | ៩០.០២ | ៨,២៣% | ១២,០០% |
| ៩០ | ១៥.៥៨ | ២,៤៣% | ២៥,០០% | ៤២ | ៥៤.៦៨ | ៥,០០% | ៥៧,០០% |
| ៦៩ | ១៥.៣៨ | ២,៤០% | ១០៧,០០% | ៦៦ | ២៣.១៧ | ២,១២% | ៧៣,០០% |
| ៥៥ | ១២.៣៦ | ១,៩៣% | ៦៦,០០% | ៦៣ | ១៣.៧០ | ១,២៥% | ៤៧,០០% |
| ៤១ | ១១.២៧ | ១,៧៦% | ១៩៦,០០% | ៨៤ | ៩.១៩ | ០,៨៤% | ២១៨,០០% |
| ៧៣ | ៨.៧២ | ១,៣៦% | ៧៤,០០% | ៤៨ | ៥.៩៥ | ០,៥៤% | ៥២១,០០% |
| ៦៣ | ៨.៣៨ | ១,៣១% | ៣,០០% | ៩៥ | ៥.៧៣ | ០,៥២% | ១៧៥,០០% |
| ០០ | ៨២.៧៧ | ១២,៩២% | ១៨,០០% | ០០ | ២៥.០៥ | ២,២៩% | ៣០,០០% |

*សម្គាល់: ៣៩៖ ប្លាស្ទិក និងវត្ថុធ្វើពីប្លាស្ទិក, ៤១៖ ស្បែកឆៅ(ក្រៅពីស្បែកជាប់រោម) និងស្បែកសម្លាប់, ៤២៖ វត្ថុធ្វើអំពីស្បែក; បរិក្ខារបំពាក់កែបសេះ និងបង្ហូរសេះ; ទំនិញសម្រាប់ការធ្វើដំណើរ កាបូបដៃ និងវត្ថុសំរាប់ផ្ទុកប្រហាក់ ប្រហែល; វត្ថុធ្វើពីពោះវៀនសត្វ(ក្រៅពីចង់សូត្រដង្កូវនាង), ៤៨៖ ក្រដាស និងក្រដាសកាតុង; វត្ថុធ្វើពីម្សៅក្រដាស ពីក្រដាស ឬពីក្រដាសកាតុង, ៦១៖ សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ ដែលធ្វើឡើងពីក្រណាត់ចាក់ដោយម្ជុលពីរ ឬមួយ, ៦២៖ សម្លៀកបំពាក់ និងគ្រឿងបន្ទាប់បន្សំ នៃសម្លៀកបំពាក់មិនធ្វើឡើងពីការចាក់ដោយម្ជុលពីរ ឬមួយ, ៦៣៖ វាយនភណ្ឌកែច្នៃរួចផ្សេងទៀត; ឈុត; សម្លៀកបំពាក់ប្រើរួច និងវត្ថុវាយនភណ្ឌបើរួច; ក្រណាត់កន្ទប, ៦៤៖ ស្បែកជើង ស្រោមជើង និងវត្ថុ ប្រហាក់ប្រហែល; ភាគរបស់វត្ថុទាំងនេះ, ៦៦៖ ឆត្រ ឆត្របាំងថ្ងៃ ឈើច្រត់ដើរ ឈើ ច្រក់សម្រាប់អង្គុយ រំពាត់ខ្សែតី រំពាត់ និងបណ្តាភាគរបស់វា ៖ ផលិតផលធ្វើពីសេរ៉ាមិច, ៧៣៖ វត្ថុធ្វើពីដែក ឬដែកថែប, ៨៤៖ រេអាទ័រនុយក្លេអ៊ែរ ធុងផលិតចំហាយ ម៉ាស៊ីន និង ឧបករណ៍មេកានិក; បំណែកភាគរបស់វា, ៨៥៖ ម៉ាស៊ីន និងឧបករណ៍អគ្គិសនី និងភាគបំណែក; ឧបករណ៍ថត និងផលិតសំឡេងឡើងវិញ, ឧបករណ៍ថត និងផលិតឡើងវិញនូវរូបភាព និង សំឡេងរបស់ទូរទស្សន៍, និងភាគបំណែក និងគ្រឿង បន្លាស់របស់ឧបករណ៍ទាំងនេះ, ៨៧៖ យាន យានយន្ត ក្រៅពីអយស្ម័យយាន ឬអយរថអគ្គិសនី បណ្តាភាគ គ្រឿងបន្លាស់ និង គ្រឿងបន្សំ, ៩០៖ ឧបករណ៍ និងបរិធានអុបទិច រូបថត ភាពយន្ត សម្រាប់វាស់វែង សម្រាប់ត្រួតពិនិត្យ សម្រាប់ពិនិត្យភាពត្រឹមត្រូវ និងសម្រាប់វេជ្ជសាស្ត្រ ឬសម្រាប់ការវះកាត់; ភាគីបំណែក និងគ្រឿង បន្ទាប់បន្សំនៃឧបករណ៍ទាំងនោះ, ៩៥៖ ប្រដាប់ប្រដាក្មេងលេង ល្បែង និង សម្ភារកីឡា; ភាគបំណែក និងគ្រឿងបន្ទាប់បន្សំ, ០០៖ ផលិតផលផ្សេងៗ។*

ប្រភព៖ អ្នកនិពន្ធគណនាពីប្រព័ន្ធទិន្នន័យ ITC Trade Map (International Trade Centre ២០២២)

តារាងទី៣ បង្ហាញពីអត្រាប្រើប្រាស់កិច្ចព្រមព្រៀង AJCEP នៃការនាំចូលរបស់ជប៉ុនពីសមាជិកអាស៊ាន។ ដោយប្រើទិន្នន័យគយនៃការនាំចូលរបស់ជប៉ុន យើងរកឃើញអត្រាប្រើប្រាស់ទាបនៃកិច្ចព្រមព្រៀង AJCEP សម្រាប់រដ្ឋសមាជិកអាស៊ានមួយចំនួន រួមមាន ថៃចន្លោះពី ១% ក្នុងឆ្នាំ២០១៣ ទៅ ៤% ក្នុងឆ្នាំ២០២១ ហ្វីលីពីនចន្លោះពី ១% ក្នុងឆ្នាំ២០១៣ ទៅ ៣% ក្នុងឆ្នាំ២០២១ និងមីយ៉ាន់ម៉ាចន្លោះពី ២% ក្នុងឆ្នាំ២០១៣ ទៅ ៨% ក្នុងឆ្នាំ២០២១។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលបង្ហាញថាព្រុយណេទំនងជាមិនប្រើប្រាស់កិច្ចព្រមព្រៀង AJCEP សម្រាប់ពាណិជ្ជកម្មរបស់ខ្លួនជាមួយជប៉ុនទេ ដោយសារការនាំចូល

របស់ជប៉ុនពីព្រុយណេមានអត្រាប្រើប្រាស់សូន្យគ្រប់ឆ្នាំទាំងអស់។ អ្វីដែលគួរឱ្យកត់សម្គាល់ក្នុងចំណោមប្រទេសសមាជិកអាស៊ាន វៀតណាមទទួលបានអត្រាប្រើប្រាស់ខ្ពស់ជាងគេចន្លោះពី ៥៧% ក្នុងឆ្នាំ២០១៣ ទៅ ៦០% នៅឆ្នាំ២០២១ បន្ទាប់មកមានម៉ាឡេស៊ី ចន្លោះពី ១៦% ទៅ ៣៣%, ឡាវចន្លោះពី ១៦% ទៅ ២៧% និងសិង្ហបុរីចន្លោះពី ១០% ទៅ ១៩% នៅក្នុងរយៈពេលដូចគ្នា។

**តារាងទី៣៖ អត្រាប្រើប្រាស់កិច្ចព្រមព្រៀង AJCEP សម្រាប់ការនាំចូលរបស់ជប៉ុនពីអាស៊ាន**

| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|---|---|---|---|---|
| ព្រុយណេ | 0,00 | 0,00 | 0,00 | 0,00 | 0,00 | 0,00 | 0,00 | 0,00 | 0,00 |
| កម្ពុជា | 0,០៨ | 0,១៤ | 0,១២ | 0,០៨ | 0,១0 | 0,០៩ | 0,០៩ | 0,១១ | 0,១៣ |
| ឥណ្ឌូនេស៊ី | 0,00 | 0,00 | 0,00 | 0,00 | 0,00 | 0,០៩ | 0,១២ | 0,១២ | 0,១២ |
| ឡាវ | 0,១៨ | 0,១៧ | 0,១៨ | 0,២៤ | 0,១៦ | 0,១៩ | 0,២២ | 0,២១ | 0,២៧ |
| ម៉ាឡេស៊ី | 0,១៦ | 0,៣៣ | 0,២៦ | 0,៣0 | 0,២៨ | 0,២៧ | 0,២៩ | 0,២៩ | 0,២៧ |
| មីយ៉ាន់ម៉ា | 0,០២ | 0,០៤ | 0,០៥ | 0,០៥ | 0,០៥ | 0,០៦ | 0,០៧ | 0,០៨ | 0,០៨ |
| ហ្វីលីពីន | 0,០១ | 0,០២ | 0,០២ | 0,០២ | 0,០៣ | 0,០២ | 0,០២ | 0,០២ | 0,០៣ |
| សិង្ហបុរី | 0,១៦ | 0,១៩ | 0,១៩ | 0,១១ | 0,១១ | 0,១១ | 0,១៣ | 0,១0 | 0,១៥ |
| ថៃ | 0,០១ | 0,០២ | 0,០២ | 0,០៣ | 0,០៣ | 0,០៤ | 0,០៥ | 0,០៤ | 0,០៤ |
| វៀតណាម | 0,៥៧ | 0,៥៧ | 0,៥៨ | 0,៦៣ | 0,៦៥ | 0,៦៤ | 0,៦៣ | 0,៦៣ | 0,៥៩ |

ប្រភព៖ អ្នកនិពន្ធគណនាពីស្ថិតិពាណិជ្ជកម្មជប៉ុន (Japan Customs ២០២២)

